ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**អគ្គនាយកដ្ឋានការងារ**
លេខៈ....៤១៧....ក.ប/អ.ក

# គោលការណ៍ណែនាំ

## ស្តីពី

## ការពិន័យចំពោះម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលប្រើប្រាស់ហត្ថពលកម្មបរទេសគ្មានប័ណ្ណការងារនិងសៀវភៅការងារ

អគ្គនាយកដ្ឋានការងារ សូមធ្វើការណែនាំដល់នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ឱ្យបានជ្រាបថា ចំពោះម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលប្រើប្រាស់ហត្ថពលកម្មបរទេសគ្មានប័ណ្ណការងារនិងសៀវភៅការងារ និងគ្មានលិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស អធិការការងារត្រូវធ្វើការពិន័យតែម្តង ដោយត្រូវអនុវត្តដូចខាងក្រោម៖

១. បើពិនិត្យឃើញថា និយោជក **"គ្មានលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស"** គឺល្មើសនឹង**មាត្រា២៦៤** និងត្រូវពិន័យដោយយោង**មាត្រា៣៦៩** នៃច្បាប់ស្តីពីការងារ ដូចមានចែងត្រង់ចំណុចទី៨៥ ក្នុងឧបសម្ព័ន្ធ នៃប្រកាសរួមលេខ៦៥៩សហវ/ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពី ការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសច្បាប់ស្តីពីការងារ នូវការពិន័យជាទឹកប្រាក់ចំនួន ១២ ៦០០ ០០០រៀល (៦៣ថ្ងៃ x ២០០ ០០០រៀល)។

២. បើពិនិត្យឃើញថា និយោជក **"ប្រើប្រាស់កម្មករនិយោជិតបរទេសដោយគ្មានប័ណ្ណការងារ និងសៀវភៅការងារ"** គឺល្មើសនឹង**មាត្រា៣៧២** និងត្រូវពិន័យដោយយោង**មាត្រា៣៧២** នៃច្បាប់ស្តីពីការងារ ដូចមានចែងត្រង់ចំណុចទី៨៦ ក្នុងឧបសម្ព័ន្ធ នៃប្រកាសរួមលេខ៦៥៩សហវ/ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសច្បាប់ស្តីពីការងារ នូវការពិន័យជាទឹកប្រាក់ក្នុងអត្រាអតិបរមា នៃពិន័យ (៦៣ថ្ងៃ x ២០០ ០០០រៀល = ១២ ៦០០ ០០០រៀល) តាមគោលការណ៍ក្នុងមាត្រា៣៨៣ នៃច្បាប់ស្តីពីការងារ ដូចខាងក្រោម៖

- បើពិនិត្យឃើញថា កម្មករនិយោជិតបរទេសដែលគ្មានបណ្ណការងារ និងសៀវភៅការងារ មានចំនួនតិចជាង **៥នាក់** អធិការការងារត្រូវពិន័យតាមចំនួនជាក់ស្តែង នៃកម្មករនិយោជិតបរទេសដែលរកឃើញថាគ្មានបណ្ណការងារ និងសៀវភៅការងារ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ឧទាហរណ៍៖

- ក្នុងករណីរកឃើញថា និយោជកប្រើប្រាស់កម្មករនិយោជិតបរទេសចំនួន ១នាក់ ដោយគ្មានបណ្ណការងារ និងសៀវភៅការងារ អធិការការងារត្រូវពិន័យ ១ដង នៃអត្រាអតិបរមានៃពិន័យ គឺ ១២ ៦០០ ០០០រៀល X ១ = ១២ ៦០០ ០០០រៀល។

- ក្នុងករណីរកឃើញថា និយោជកប្រើប្រាស់កម្មករនិយោជិតបរទេសចំនួន ២នាក់ ដោយគ្មានបណ្ណការងារ និងសៀវភៅការងារ អធិការការងារត្រូវពិន័យ ២ដង នៃអត្រាអតិបរមានៃពិន័យ គឺ ១២ ៦០០ ០០០រៀល X ២ = ២៥ ២០០ ០០០រៀល។

- ក្នុងករណីរកឃើញថា និយោជកប្រើប្រាស់កម្មករនិយោជិតបរទេសចំនួន ៣នាក់ ដោយគ្មានបណ្ណការងារ និងសៀវភៅការងារ អធិការការងារត្រូវពិន័យ ៣ដង នៃអត្រាអតិបរមានៃពិន័យ គឺ ១២ ៦០០ ០០០រៀល X ៣ = ៣៧ ៨០០ ០០០រៀល។

- ក្នុងករណីរកឃើញថា និយោជកប្រើប្រាស់កម្មករនិយោជិតបរទេសចំនួន ៤នាក់ ដោយគ្មានបណ្ណការងារ និងសៀវភៅការងារ អធិការការងារត្រូវពិន័យ ៤ដង នៃអត្រាអតិបរមានៃពិន័យ គឺ ១២ ៦០០ ០០០រៀល X ៤ = ៥០ ៤០០ ០០០រៀល។

- បើពិនិត្យឃើញថា កម្មករនិយោជិតបរទេសដែលគ្មានបណ្ណការងារ និងសៀវភៅការងារ មានចំនួនចាប់ពី ៥នាក់ ឡើងទៅ អធិការការងារត្រូវពិន័យ ៥ដង នៃអត្រាអតិបរមានៃពិន័យ នូវការពិន័យជាទឹកប្រាក់ចំនួន ៦៣ ០០០ ០០០រៀល (១២ ៦០០ ០០០រៀល X ៥)។

ឧទាហរណ៍៖

- ក្នុងករណីរកឃើញថា និយោជកប្រើប្រាស់កម្មករនិយោជិតបរទេសចំនួន ៥នាក់ ដោយគ្មានបណ្ណការងារ និងសៀវភៅការងារ អធិការការងារត្រូវពិន័យ ៥ដង នៃអត្រាអតិបរមានៃពិន័យ គឺ ១២ ៦០០ ០០០រៀល X ៥ = ៦៣ ០០០ ០០០រៀល។

- ក្នុងករណីរកឃើញថា និយោជកប្រើប្រាស់កម្មករនិយោជិតបរទេសចំនួន ៩នាក់ ដោយគ្មានបណ្ណការងារ និងសៀវភៅការងារ អធិការការងារត្រូវពិន័យ ៥ដង នៃអត្រាអតិបរមានៃពិន័យ គឺ ១២ ៦០០ ០០០រៀល X ៥ = ៦៣ ០០០ ០០០រៀល។

ថ្ងៃអង្គារ ១១រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ**

**សេង_សក្ដា**